ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ភ្នំពេញ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០១៦

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## កិច្ចប្រជុំវេទិកាពន្ធអន្តរជាតិ ក្រោមប្រធានបទ "គោលនយោបាយសារពើពន្ធ និងកំណើនសេដ្ឋកិច្ច" រដ្ឋធានីម៉ានីឡា នៃប្រទេសហ្វីលីពីន ថ្ងៃទី២៧-២៨ ខែតុលា ឆ្នាំ២០១៦




© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

តបតាមការអញ្ជើញរបស់ ក្រសួងហិរញ្ញវត្ថុ នៃប្រទេសហ្វីលីពីន ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងជាតំណាងរបស់ ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អមដំណើរដោយឯកឧត្តម អ៊ុំ សីហា អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ បានដឹកនាំ គណៈប្រតិភូនៃអគ្គនាយកដ្ឋានពន្ធដារ រួមមាន លោកប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និងមន្ត្រីជំនាញមួយចំនួនទៀត ដើម្បីចូលរួមកិច្ចប្រជុំវេទិកាពន្ធអន្តរជាតិ ក្រោមប្រធានបទ "គោលនយោបាយសារពើពន្ធនិងកំណើនសេដ្ឋកិច្ច" ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ នារដ្ឋធានីម៉ានីឡា នៃប្រទេសហ្វីលីពីន ។ កិច្ចប្រជុំជាលក្ខណៈអន្តរជាតិនេះ ក៏មានការចូលរួមពីសំណាក់គណៈប្រតិភូមកពីបណ្តាប្រទេសនានានៅក្នុងតំបន់អាស៊ាន អាមេរិកឡាទីន និងអឺរ៉ុប ព្រមទាំងតំណាងអង្គការអន្តរជាតិធំៗមួយចំនួន ដូចជា IMF, World Bank និង OECD ជាដើម ដើម្បីធ្វើការពិភាក្សាលើប្រធានបទសំខាន់ៗ ពាក់ព័ន្ធនឹងគោលនយោបាយសារពើពន្ធ និងកំណើនសេដ្ឋកិច្ចរួម ទាំងក្នុងក្របខ័ណ្ឌតំបន់ ក៏ដូចជាក្របខ័ណ្ឌពិភពលោកទាំងមូល។

ពេលអញ្ជើញដល់រដ្ឋធានីម៉ានីឡា នៃប្រទេសហ្វីលីពីន គណៈប្រតិភូកម្ពុជា ដឹកនាំដោយឯកឧត្តម គង់ វិបុល បានទទួលនូវបដិសណ្ឋារកិច្ច និងកិច្ចស្វាគមន៍យ៉ាងកក់ក្តៅ ពីសំណាក់



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

ក្រសួងហិរញ្ញវត្ថុហ្វីលីពីននៃប្រទេសហ្វីលីពីន ដែលជាម្ចាស់ផ្ទះក្នុងការរៀបចំនៃកិច្ចប្រជុំខាងលើ។ ជាមួយគ្នានេះដែរ ក៏មានការរៀបចំនូវពិធីលាងសាយភោជន៍នាល្ងាចថ្ងៃទី២៧ ខែតុលា ឆ្នាំ ២០១៦ ដោយប្រទេសម្ចាស់ផ្ទះ ដើម្បីទទួលស្វាគម៍ចំពោះគណៈប្រតិភូទាំងអស់ ដោយមានការប្រគុំតន្ត្រីប្រពៃណីកំដរក្នុងកំឡុងពេលលាងសាយភោជន៍ផងដែរ។

សូមបញ្ជាក់ថា កិច្ចប្រជុំលក្ខណៈអន្តរជាតិសម្រាប់ រយៈពេល ២ថ្ងៃខាងលើ មានការផ្តោតយកចិត្តទុកដាក់ ទៅលើការចែករំលែកបទពិសោធន៍ ក្នុងការអនុវត្តជាក់ស្តែង ពាក់ព័ន្ធទៅនឹងការរៀបចំនូវគោលនយោបាយសារពើពន្ធថ្មីៗ ពីបណ្តាប្រទេសនានា ដែលអាចជះឥទ្ធិពលដល់កំណើនសេដ្ឋកិច្ចរួម និងការកាត់បន្ថយភាពក្រីក្រ។ កិច្ចប្រជុំក៏បានរួមបញ្ចូលនូវរបៀបវារៈសំខាន់ៗជាច្រើនសម្រាប់រយៈពេលពីរថ្ងៃបន្តបន្ទាប់ដូចខាងក្រោម៖

1. ការកាត់បន្ថយនូវភាពមិនស្មើគ្នា ពាក់ព័ន្ធនឹងចំណូល និងការបែងចែកនូវចំណូលឡើងវិញ (Reducing Income Inequality and Enhancing Wealth Redistribution)

2. ការយកពន្ធដើម្បីសុខភាព និងការការពារបរិស្ថាន (Taxation for Health Promotion and Environmental Protection)

3. គោលនយោបាយសារពើពន្ធ ក្នុងបរិបទសេដ្ឋកិច្ចទីផ្សារសេរី (Fiscal Policy and Open Economy)

4. ការពង្រឹងផ្នែកសារពើពន្ធ និងទប់ស្កាត់នូវភាពខ្វះចន្លោះក្នុងការយកពន្ធ (Fiscal Discipline and Addressing Leakages)

សម្រាប់របៀបវារៈនីមួយៗ គឺត្រូវបានចែកចេញជាប្រធានបទតូចៗលម្អិតបន្ថែមទៀត ដោយមានការធ្វើបទបង្ហាញ និងពិភាក្សាវែកញែករបស់វាគ្មិនមកពីបណ្តាប្រទេស និងស្ថាប័នអន្តរជាតិនានាដើម្បីធ្វើការផ្លាស់ប្តូរបទពិសោធន៍ទៅវិញទៅមក សំដៅធ្វើយ៉ាងណាឲ្យកិច្ចប្រជុំទទួលបានលទ្ធផលជាផ្លែផ្កាជាវិជ្ជមាន។

នៅល្ងាចថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៦ គណៈប្រតិភូកម្ពុជាក៏បានធ្វើដំណើរនិវត្តន៍មកដល់ប្រទេសកម្ពុជា ដោយសុវត្ថិភាព និងដោយជោគជ័យ ហើយក៏បានពាំនាំយកមកនូវបទពិសោធន៍ និងចំណេះដឹងល្អៗ សម្រាប់ជាធាតុចូលថ្មីៗបន្ថែមទៀតដល់ការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងការកែទម្រង់ចំពោះប្រព័ន្ធពន្ធដារកម្ពុជាទាំងមូល សម្រាប់គោលដៅប្រសិទ្ធភាព និងសក្តិសិទ្ធភាពបន្ថែមទៀត ជាពិសេសជំរុញឲ្យប្រព័ន្ធពន្ធដារកម្ពុជា មានសង្គតិភាពជាមួយបណ្តាប្រទេសនានានៅក្នុងតំបន់ក៏ដូចជាក្នុងសកលលោក៕



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ